TSEMP-C2 ឯកសារបណ្តុះបណ្តាល No.2

# គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២

## ការរៀបចំសហគមន៍ដើម្បីគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព



# ការរៀបចំផែនការសកម្មភាពសហគមន៍នេសាទ

ទូច គឹមរាន  គឹម សុវណ្ណ  សៀក សុលី និង យៀប ម៉ឿង

Technical Assistance by

Food and Agricultural Organization of the United Nations FAO

Project Support Office Siem Reap

Made possible under

Tonle Sap Environmental Management Project

ADB Loan No.1939-CAM (SF)

ឧបត្ថម្ភដោយ៖
ការិយាល័យអនុវត្តគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប
នៃរដ្ឋបាលជលផល (TSEMP-C2/ FiA)

ម.ព.ឯ.ក AIDOC
Code: 133-004
Date:
Donated by:

# ការរៀបចំផែនការសកម្មភាព
# សហគមន៍នេសាទ

**កែសម្រួលដោយៈ**

លោក សេង ជាសាន អនុប្រធានរដ្ឋបាលជលផល និងជាប្រធានការិយាល័យអនុវត្តគម្រោង
លោក ឈី ទុន្នី ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងជាជំនួយការនៃការិយាល័យអនុវត្តគម្រោង
លោក ពេជ ម៉ុនណា អនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងជាមន្ត្រីត្រួតពិនិត្យតាមខេត្តនៃការិយាល័យអនុវត្តគម្រោងសម្រាប់ខេត្តកំពង់ធំ-សៀមរាប
លោក ឈួន គឹមឈា អនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងជាមន្ត្រីត្រួតពិនិត្យតាមខេត្តនៃការិយាល័យអនុវត្តគម្រោងសម្រាប់ខេត្តកំពង់ឆ្នាំង-ពោធិ៍សាត់
លោក អ៊ុយ ជីខ មន្ត្រីត្រួតពិនិត្យតាមខេត្តនៃការិយាល័យអនុវត្តគម្រោងសម្រាប់ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ

**រចនាដោយៈ**

លោក ជៀង ស៊ីសុទិន អ្នកចាត់ការការិយាល័យគាំទ្រគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២
កញ្ញា ពុធ ណារិន ជំនួយការការិយាល័យគាំទ្រគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២

រូបថតគម្របក្រៅ : *ការសម្របសម្រួលធ្វើផែនការសកម្មភាពសហគមន៍នេសាទនៅខេត្តបាត់ដំបង*
ថតដោយ : *មន្ត្រីអនុវត្តគម្រោងខេត្តបាត់ដំបង*

បោះពុម្ពផ្សាយដោយ:

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ
គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២
ការិយាល័យនាំមុខគម្រោង
ផ្ទះលេខ ៥ ផ្លូវ ៣៧០ សង្កាត់បឹងកេងកងទី១
ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣  ២១១ ៧០២
ទូរសារលេខ: (៨៥៥) ២៣ ២១៦ ៥៤៧
អ៊ីម៉ែល: FAO-KH@fao.org

សហការជាមួយ:
រដ្ឋបាលជលផល
គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២
ការិយាល័យអនុវត្តគម្រោង
អាគារលេខ ១៨៦, មហាវិថីព្រះនរោត្តម,
ប្រអប់សំបុត្រ ៥៨២, រាជធានីភ្នំពេញ, កម្ពុជា
ទូរស័ព្ទ / ទូរសារលេខ: (៨៥៥) ២១៥ ៤៧០
អ៊ីម៉ែល: cfdd@yahoo.com

សេចក្តីពិពណ៌នា ចំណងជើងអត្ថបទ ឬព័ត៌មានក្នុងអត្ថបទបោះពុម្ពផ្សាយនេះ មិនមែនជាទស្សនៈរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ឬក៏ជាទស្សនៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ីឡើយ ទាក់ទិននឹងច្បាប់ ឬស្ថានភាពអភិវឌ្ឍន៍ របស់ប្រទេសណាមួយឡើយ ទឹកដី ទីក្រុង ឬតំបន់ ឬអំពីសិទ្ធិអំណាច ឬមួយទាក់ទិនទៅនឹងការកំណត់ព្រំដែន ។ ទស្សនៈយោបល់ដែលបានបង្ហាញនៅក្នុងអត្ថបទបោះពុម្ពផ្សាយនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះ ។

# សេចក្តីថ្លែងអំណរគុណ


ឯកសារបណ្តុះបណ្តាលស្តីពី "**ការរៀបចំផែនការសកម្មភាពសហគមន៍នេសាទ**" នេះត្រូវបានរៀបចំចងក្រងឡើង ដោយការិយាល័យគាំទ្រគម្រោង នៃគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២ ដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់ និងតម្រូវការ ក្នុងការផ្តល់បច្ចេកទេស និងបទពិសោធន៍ដល់អ្នកសម្របសម្រួលសហគមន៍នេសាទ ក៏ដូចជាគណៈកម្មការសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីជួយសហគមន៍នេសាទក្នុងការរៀបចំផែនការរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។

ក្រុមការងារនៃការិយាល័យគាំទ្រគម្រោង សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់រដ្ឋបាលជលផល ជាពិសេស ឯកឧត្តម **ណៅ ធូក** ប្រធានរដ្ឋបាលជលផល ដែលបានគាំទ្រនិងជួយសម្របសម្រួល និងធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ឥណទានសម្បទាន [ADB Loan No.1939-CAM (SF)] និងថវិកាបដិភាគរាជរដ្ឋាភិបាលកម្ពុជាសម្រាប់អនុវត្តគម្រោង ដោយមានការគាំទ្របច្ចេកទេសដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ។

ក្រុមការងារនៃការិយាល័យគាំទ្រគម្រោង សូមថ្លែងអំណរគុណដ៏ពន្លឹកដល់លោក **អេង ជាសាន** អនុប្រធានរដ្ឋបាលជលផល និងប្រធានការិយាល័យអនុវត្តគម្រោង និងលោក **លី វុទ្ធី** ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងជាជំនួយការរបស់គម្រោង និងមន្ត្រីត្រួតពិនិត្យៈ លោក **ពេជ ប៊ុនណា** លោក **ឈួន គឹមឈា** និងលោក **អ៊ុយ ជឹង** ដែលបាន ជួយកែសម្រួលឱ្យឯកសារបណ្តុះបណ្តាលនេះកាន់តែមានភាពសុក្រឹត្យ និងសមស្របទៅនឹង ស្ថានភាពបច្ចុប្បន្ន និងសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រដល់មន្ត្រីសមភាគីគម្រោង ជំនាញរៀបចំសហគមន៍ និងជំនាញសហគមន៍នេសាទ នៅតាមបណ្តាខេត្តទាំង៥ៈ ខេត្តបាត់ដំបង លោក **អន សុខា** និង លោក **ហេង ពិសិដ្ឋ** ខេត្តពោធិ៍សាត់ លោក **ផា ស្រួយ** និងលោក **រស់ គន្ធី** ខេត្តកំពង់ឆ្នាំង លោក **ហ៊ត ស៊ីថា** និងលោក **ប៊ុន រ៉ាស៊ី** ខេត្តកំពង់ធំ លោក **តាន់ មូលី** និងលោក **ឡេង សំអាត** ខេត្តសៀមរាប លោក **ចាន់ តុង** និងកញ្ញា **កែវ សុវត្ថិភាព** ដែលបានចំណាយពេលវេលា និងកម្លាំងកាយចិត្តជួយផ្តល់អនុសាសន៍ ពិនិត្យផ្ទៀងផ្ទាត់ និងកែលំអឯកសារបណ្តុះបណ្តាលនេះ ឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើង។

ទោះជាយ៉ាងណាក៏ដោយ ក្រុមការងារនៃការិយាល័យគាំទ្រគម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-ផ្នែកទី២ សង្ឃឹមទុកជាមុន និងទទួលយកជានិច្ចរាល់មតិយោបល់កែលំអក្នុងន័យស្ថាបនាដល់យើងខ្ញុំ ។

## មាតិកាអត្ថបទ


១. សេចក្តីផ្តើម ........................................ ១

២. គោលបំណងនៃវគ្គបណ្តុះបណ្តាល ........................................ ១

៣. និយមន័យផែនការនិងសកម្មភាព ........................................ ២

៤. ហេតុអ្វីត្រូវមានផែនការសកម្មភាព ........................................ ៣

៥. អ្នកណាជាអ្នករៀបចំផែនការសកម្មភាព ........................................ ៣

៦. ដំណើរការរៀបចំផែនការសកម្មភាព ........................................ ៤

**ក. ការរំលឹកឡើងវិញពីសកម្មភាពដែលគ.ស.ន.បានធ្វើកន្លងមក** ........................................ ៤

**ខ. ការកំណត់បញ្ហាសំខាន់ៗដែលពុំទាន់ដោះស្រាយ និងបន្តដោះស្រាយ** ........................................ ៥

**គ. ការចាត់អាទិភាពបញ្ហា** ........................................ ៥

**ឃ. ការកំណត់/បង្កើតគោលបំណង និងលទ្ធផលរំពឹងទុក** ........................................ ៦

**ង. ការកំណត់សកម្មភាពចំបង និងធាតុផ្សេងៗនៃតារាងផែនការ** ........................................ ៧

**ច. ការស្នើគាំទ្រពីសំណាក់អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ** ........................................ ១០

**ឆ. ការអនុវត្តផែនការសកម្មភាព និងការត្រួតពិនិត្យ** ........................................ ១០

៧. ឯកសារពិគ្រោះ ........................................ ១៤

៨. ឯកសារជំនួយ ........................................ ១៥




រូបភាពទី ១: សកម្មភាពរៀបចំរៀបចំផែនការសកម្មភាពរបស់គណៈកម្មការសហគមន៍នេសាទ

## ១. សេចក្តីផ្តើមៈ

យោងតាមតម្រូវការជាក់ស្តែង និងដើម្បីងាយស្រួលដល់ស្ថាប័នពាក់ព័ន្ធ អាចជួយសម្រួលការងាររបស់សហគមន៍ គណៈកម្មការសហគមន៍ត្រូវមានផែនការសកម្មភាពប្រចាំខែ ឬត្រីមាសរបស់ខ្លួន ។ អនុលោមតាមភាពចាំបាច់នេះ វគ្គបណ្តុះបណ្តាលស្តីពី ***"ការរៀបចំផែនការសកម្មភាពសហគមន៍នេសាទ"*** ត្រូវបានរៀបចំឡើងសម្រាប់ក្រុមការងារអនុវត្តគម្រោង ដើម្បីជួយដល់គណៈកម្មាការសហគមន៍នេសាទ ដែលស្ថិតនៅក្នុងតំបន់បំរុងជីវមណ្ឌលបឹងទន្លេសាប ។

ផែនការសកម្មភាពនេះនឹងជួយអោយគណៈកម្មការសហគមន៍នេសាទ ឱ្យចេះគិតគូរប្រមើលមើលពីការងារដែលត្រូវធ្វើនាពេលអនាគត(រយៈពេលខ្លី និងវែង)ដើម្បីអភិវឌ្ឍន៍សហគមន៍នេសាទ ក៏ដូចជាធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់សមាជិកសហគមន៍។ ហើយទន្ទឹមនឹងនេះ គណៈកម្មការសហគមន៍នេសាទក៏អាចយល់ដឹងអំពីទស្សនៈទាន និងវិធីសាស្ត្រនៃការរៀបចំផែនការសកម្មភាព សម្រាប់ការអភិវឌ្ឍសហគមន៍នេសាទ ដែលទាក់ទងនឹងតួនាទី តម្រូវការពេលវេលា ថវិកា អ្នកអនុវត្ត លទ្ធផលរំពឹងទុក និងស្ថាប័នជំនាញដែលចាំបាច់ត្រូវតែធ្វើការសហការជាមួយ ដើម្បីធ្វើការគាំទ្រដល់ការអនុវត្តផែនការសហគមន៍នេសាទឱ្យបានល្អប្រសើរ ។

ដោយយោងទៅតាមស្មារតីអនុក្រឹត្យ *ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ* (មាត្រាទី២០) គណៈកម្មការសហគមន៍ត្រូវមានភារកិច្ចរៀបចំផែនការរយៈពេលខ្លី រយៈពេលវែង និងអនុវត្តប្រកបដោយប្រសិទ្ធភាព។ ម្យ៉ាងវិញទៀត សហគមន៍នេសាទជាអង្គការមួយដែលមានរូបរាងរួចមកហើយ ហើយក៏ជាពេលដែលត្រូវមានផែនការសកម្មភាពរបស់ខ្លួន ដើម្បីតម្រង់ទិសដៅការអនុវត្តការងារផងដែរ។

- តើការងារចាំបាច់អ្វីខ្លះ ដែលសហគមន៍ត្រូវធ្វើក្នុងរយៈពេលខ្លីខាងមុខ?
- តើអ្នកសម្របសម្រួល មានភារកិច្ចបែបណា ទាក់ទងទៅនឹងផែនការសកម្មភាពរបស់សហគមន៍?
- តើត្រូវមានការគាំទ្រអ្វីខ្លះ ដើម្បីឱ្យផែនការសកម្មភាពរបស់សហគមន៍មានលក្ខណៈប្រាកដប្រជា?
- តើត្រូវមានប្រព័ន្ធរាយការណ៍ដូចម្តេច ក្រោយពីផែនការសកម្មភាពត្រូវបានអនុវត្ត?
- តើការទុកដាក់ឯកសារមានលក្ខណៈដូចម្តេច?

## ២. គោលបំណងនៃវគ្គបណ្តុះបណ្តាលៈ

ដើម្បីជួយគាំទ្រអ្នកសម្របសម្រួលនិង គណៈកម្មការសហគមន៍នេសាទឱ្យមានលទ្ធភាពគ្រៀម និងរៀបចំផែនការសកម្មភាពប្រចាំខែ និងត្រីមាសសម្រាប់ការងារគ្រប់គ្រងធនធានជលផល ។ ផែនការសកម្មភាពជាមូលដ្ឋានគ្រឹះ សម្រាប់ព្រាងការងារដែលត្រូវអនុវត្ត និងស្វ័យត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំនូវការអនុវត្តការគ្រប់គ្រងធនធានជលផលរបស់សហគមន៍នេសាទរបស់ខ្លួន ។ ជាក់ស្តែងផែនការសកម្មភាពនឹងផ្តល់ជាគំនិត ឱ្យគណៈកម្មការសហគមន៍នូវៈ

- ការប្រមើលមើលទូលាយនូវទិដ្ឋភាពដែលនឹងត្រូវធ្វើនៅពេលខាងមុខ
- ការកំណត់នូវទិសដៅ គោលបំណង និងលទ្ធផលរំពឹងទុករយៈពេលខ្លី (ក្នុងដំណាក់កាលដំបូង) និងរយៈពេលវែងនៅពេលណាដែលគេយល់ច្បាស់ និងអនុវត្តទូលំទូលាយនូវផែនការសកម្មភាព
- ការទទួលបាននូវកិច្ចព្រមព្រៀងលើការអនុវត្តផែនការក្នុងចំណោមសមាជិកសហគមន៍នេសាទ
- ការចូលរួមពីសំណាក់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធផ្សេងៗក្នុងការងារអភិវឌ្ឍន៍ សហគមន៍នេសាទ ។

## ៣. និយមន័យផែនការ និងសកម្មភាព:

***ផែនការមានន័យដូចម្តេច?***

ជាការគិតទុកជាមុននូវអ្វីដែលនឹងត្រូវធ្វើ និងតម្រូវការផ្សេងៗនាពេលអនាគតដើម្បីសម្រេចបាននូវគោលដៅដែលចង់បាន ។ គឺជាបណ្តុំនៃសកម្មភាព ដែលទាក់ទងគ្នាទៅវិញទៅមក ដែលរួមចំណែកសម្រេចគោលបំណងទៅតាមធនធានដែលមាន និងក្នុងកំឡុងពេលកំណត់មួយ ។

***សកម្មភាពជាអ្វី?***

សកម្មភាព គឺជាជំហានតូចៗតាមលំដាប់លំដោយ ដែលជួយយើងឱ្យឈានទៅដល់ការសម្រេចបាននូវគោលបំណង និងលទ្ធផលរំពឹងទុករបស់សហគមន៍នេសាទ ។ ដើម្បីសម្រេចគោលបំណងជាទូទៅសកម្មភាពមានលក្ខណៈដូចខាងក្រោម:

- បន្ថែមព័ត៌មានលំអិតឱ្យគោលបំណង និងលទ្ធផលរំពឹងទុក
- មានពេលវេលាចាប់ផ្តើម និងពេលបញ្ចប់ច្បាស់លាស់
- ទាមទារឱ្យមានមធ្យោបាយ ឬធនធានដើម្បីសម្រេច ។ ឧទាហរណ៍ដូចជា ថវិកា បុគ្គលិក និងសម្ភារៈឧបករណ៍ជាដើម ។
- មានលទ្ធផលច្បាស់លាស់ ហើយមានសន្ទស្សន៍ដែលឋិតនៅក្រោមការត្រួតពិនិត្យរបស់យើង

***<u>ឧទាហរណ៍:</u>***

- ក្រុមស្ថាបនិក ឬគណៈកម្មការ បែងចែកការងារក្នុងការចុះឈ្មោះសមាជិក
- ក្រុមល្បាតរបស់សហគមន៍ចុះល្បាតព្រៃលិចទឹក និងដែននេសាទនៅសប្តាហ៍ក្រោយ

## ៤. ហេតុអ្វី សហគមន៍នេសាទត្រូវមានផែនការសកម្មភាព?

សហគមន៍នេសាទ ដែលដឹកនាំដោយគណៈកម្មការ ត្រូវមានផែនការសកម្មភាពរបស់ខ្លួន ដើម្បីឱ្យសហគមន៍:

- អនុលោមទៅតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- ត្រៀមខ្លួនដើម្បីរៀបចំ ***ផែនការគ្រប់គ្រងសហគមន៍នេសាទ*** នាពេលខាងមុខ
- ត្រៀមធនធានមនុស្ស ថវិកា ពេលវេលា និងសម្ភារៈ
- កំណត់ទិសដៅនៃដំណើរការអនុវត្តសកម្មភាពទាំងឡាយឈានទៅរកការសម្រេចនូវជោគជ័យ
- មានភាពប្រាកដនិយមក្នុងការអនុវត្តកិច្ចការ
- ងាយស្រួលក្នុងការបែងចែកភារកិច្ច ការទទួលខុសត្រូវលើកិច្ចការងារ
- មានឧបករណ៍ជំនួយដល់ការតាមដាន និងវាយតម្លៃ
- ផ្តល់ដល់អ្នកពាក់ព័ន្ធដើម្បីងាយស្រួលក្នុងការជួយគាំទ្រ

## ៥. អ្នកណាជាអ្នករៀបចំផែនការសកម្មភាព?

ផែនការសកម្មភាពត្រូវបានបង្កើតឡើងដោយក្រុមការងារមួយក្រុមរួមមាន:

- គណៈកម្មការសហគមន៍
- សមាជិកសហគមន៍
- អាជ្ញាធរមូលដ្ឋាន
- អ្នកសម្របសម្រួល-ក្រុមការងារអនុវត្តគម្រោង
- អ្នកពាក់ព័ន្ធនានា

ដើម្បីធានាថាផែនការសកម្មភាពដែលបានរៀបចំ មានភាពប្រាកដប្រជាអាចយកទៅអនុវត្តបានផែនការសកម្មភាពនោះត្រូវរៀបចំឱ្យមានលក្ខណៈដូចខាងក្រោម:

- ភាពសាមញ្ញប៉ុន្តែល្អិតល្អន់
- សមស្របតាមកាលៈទេសៈពេលវេលា និងស្ថានភាពជាក់ស្តែងនៅសហគមន៍
- អាចវាស់វែងបាន
- មានការពេញចិត្តចូលរួមអនុវត្ត
- អាចសម្រេចទៅបាន (មិនត្រូវមានមហិច្ឆិតាហួសហេតុ)

ដូច្នេះរាល់ការរៀបចំផែនការសកម្មភាព សម្រាប់សហគមន៍នេសាទចាំបាច់ទាមទារឱ្យសមាជិកគណៈកម្មការសហគមន៍នេសាទម្នាក់ចូលរួមឱ្យបានផុលផុស ។ ត្រូវអញ្ជើញប្រធានភូមិ ឬតំណាងសមាជិកក្រុមប្រឹក្សាឃុំ និងអ្នកដែលពាក់ព័ន្ធនានា (អង្គការក្រៅរដ្ឋាភិបាល...) ចូលរួមក្នុងដំណើររៀបចំផែនការសកម្មភាពនេះ ដើម្បីទទួលបាននូវការគាំទ្រទាំងបច្ចេកទេស ថវិកា និងកិច្ចសហការ ។

## ៦. ដំណើរការរៀបចំផែនការសកម្មភាព

មុននឹងចាប់ផ្តើមរៀបចំផែនការសកម្មភាព គណៈកម្មការសហគមន៍នេសាទត្រូវគិតថា តើមានសកម្មភាពសំខាន់ៗអ្វីខ្លះដែលបានធ្វើកន្លងមក ត្រូវលើកយកមកពិភាក្សា និងដោះស្រាយចំពោះមុខ ។ ជំហានសំខាន់ៗដើម្បីរៀបចំផែនការសកម្មភាពរបស់សហគមន៍នេសាទប្រកបដោយប្រសិទ្ធភាពរួមមានៈ




យើងនឹងពិនិត្យមើលម្តងមួយៗតាមលំដាប់លំដោយ ដូចខាងក្រោមៈ

### ក. ការរំលឹកឡើងវិញពីសកម្មភាពដែលគណៈកម្មការសហគមន៍នេសាទបានធ្វើកន្លងមក

នេះជាការឆ្លុះបញ្ចាំងឡើងពីសកម្មភាព ដែលសហគមន៍បានធ្វើកន្លងមក ដើម្បីរួមចំណែកដល់ការបង្កើត និងអភិវឌ្ឍន៍សហគមន៍នេសាទមកដល់ពេលនេះ ។ ការងារនេះផ្តោតទៅលើចំណុចគន្លឹះនៃស្ថានភាពល្អប្រសើរ និងស្មុគស្មាញដែលមាននៅក្នុងសហគមន៍ ។ ភាពទូលំទូលាយនៃការរៀបចំផែនការសកម្មភាពល្អត្រូវកំណត់ដោយបរិមាណ

ព័ត៌មានដែលអាចរកបាន (មានព័ត៌មានច្រើន និងវិភាគគ្រប់ជ្រុងជ្រោយ) ភាពស្មុគស្មាញនៃបញ្ហាដែលត្រូវរកផ្លូវដោះស្រាយ (ដោះស្រាយតែបញ្ហាណាដែលគិតថាអាចធ្វើទៅបាន)។ មានការងារខ្លះត្រូវបន្តធ្វើឱ្យល្អថែមទៀត ។ ការងារខ្លះទៀតត្រូវដោះស្រាយទៅតាមសមត្ថភាព និងលទ្ធភាពដែលសហគមន៍មាន ។ ការងារខ្លះទៀតហួសពីសមត្ថភាពសហគមន៍ដែលទាមទារឱ្យមានការគាំទ្រពីអ្នកពាក់ព័ន្ធផ្សេងទៀត ។

**ខ. ការកំណត់បញ្ហាសំខាន់ៗដែលពុំទាន់ដោះស្រាយ និងបន្តដោះស្រាយ**

ជំហាននេះតម្រូវឱ្យគណៈកម្មការសហគមន៍នេសាទ ត្រូវកំណត់រាល់បញ្ហាសំខាន់ៗដែលបានអនុវត្តកន្លងមកដោយបញ្ជាក់ឱ្យបានច្បាស់ថា តើបញ្ហាណាដែលមិនទាន់បានដោះស្រាយមកពីមូលហេតុអ្វី? តើត្រូវយកមកដោះស្រាយ បន្ត ឬក៏ដោះស្រាយនៅពេលក្រោយ ?

- កំណត់បញ្ហាដែលមានស្រាប់អាចដោះស្រាយបាន និងបញ្ហាដែលអាចមានជាយថាហេតុនាពេលខាងមុខ
- បញ្ហានានាត្រូវតែមានដំណោះស្រាយ ដែលអាចទទួលយកមកអនុវត្តបាន
- ចូរអ្នកផ្តោតលើបញ្ហាសំខាន់ៗទាក់ទងទៅនឹងធនធានធម្មជាតិ ជាពិសេសធនធានជលផល
- បទល្មើសផ្សេងៗដែលកើតឡើងនៅក្នុងសហគមន៍
- ចំណុចខ្វះខាត ក្នុងដំណើរការបង្កើត និងអភិវឌ្ឍន៍សហគមន៍ (លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រង)
- សមត្ថភាពគណៈកម្មការសហគមន៍នេសាទ និងការយល់ដឹងរបស់សមាជិក
- ទំលាប់នៃការប្រកបរបរចិញ្ចឹមជីវិត (ការរានដីព្រៃលិចទឹក ការប្រើប្រាស់ថ្នាំពុល និងជីគីមី)
- បង្កើនជីវភាពរស់នៅតាមរយៈការបង្កើនមុខរបរ (ចិញ្ចឹមត្រី ដាំបន្លែ ទុនសន្សំ កែច្នៃផលិតផល)។

**គ. ការចាត់អាទិភាពបញ្ហា**

ក្រោយពីកំណត់បានបញ្ហាសំខាន់ៗរួចហើយ ការចាត់អាទិភាពទៅលើបញ្ហាទាំងនោះ ត្រូវបានធ្វើឡើងដោយអនុវត្តតាមវិធីដូចខាងក្រោម៖

- ធ្វើចំណាត់ថ្នាក់បញ្ហា ដែលបានលើកឡើងដោយផ្តល់ពិន្ទុ (សំខាន់ណាស់ បង្គួរ មធ្យម)
- ប្រើប្រាស់តារាងប្រៀបធៀបភាពសំខាន់នៃបញ្ហា (ម៉ាទ្រិច ការពិភាក្សា និងព្រមព្រៀងមតិ)

ការចាត់អាទិភាពបញ្ហាបង្កលក្ខណៈងាយស្រួល ឱ្យយើងអាចរៀបចំផែនការសកម្មភាពបានចំគោលដៅ ដែលកំពុងកើតឡើងជាក់ស្តែង និងចាំបាច់ក្នុងមូលដ្ឋានរបស់យើង ។

**ឃ. ការកំណត់ / បង្កើតគោលបំណង និងលទ្ធផលរំពឹងទុក**

ក្រោយអ្នកបានកំណត់បញ្ហា និងចាត់អាទិភាពបញ្ហាទាំងនោះរួចហើយ ពេលនេះអ្នកត្រូវសរសេរគោលបំណងដែលត្រូវនឹងបញ្ហានីមួយៗ ។ ជួនកាលបញ្ហាវាសំដែងចេញជាលក្ខណៈអវិជ្ជមាន( អ្នកត្រូវសរសេរឱ្យទៅជាប្រយោគវិជ្ជមានដែលសំដែងជាលទ្ធផលរំពឹងទុក) ។ តើមានវិធីយ៉ាងណាខ្លះដើម្បីបង្កើតគោលបំណង ?

***ប្រើស្មាត (SMART)***

គោលបំណងត្រូវសរសេរឱ្យចេញជាលទ្ធផលដែលអ្នកទទួលផលអាចទទួលបាន ។

**ស្មាត** (SMART) មានន័យពេញដូចខាងក្រោម:

- **S = Specific** មានភាពជាក់លាក់ ច្បាស់
- **M = Measurable** អាចវាស់វែងបាន
- **A = Attainable** អាចសម្រេចបានដោយសង្កត់ធ្ងន់លើធនធានដែលអ្នកមាន
- **R = Realistic** ប្រាកដប្រជា
- **T = Time Bound and Timely** ពេលវេលាច្បាស់លាស់ (ផ្តើម-បញ្ចប់)

**ឧទាហរណ៍ : គោលបំណង**

នៅដំណាច់ ខែធ្នូ ឆ្នាំ ២០០៧ សហគមន៍នេសាទចំនួន ១៧៤ នឹងទទួលបានការទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

ចូរអ្នកសាកល្បងវិភាគទៅមើល ថាតើចំណុចណាដែលបញ្ជាក់ :

- ការងារជាក់លាក់ ច្បាស់
- អាចវាស់វែងលទ្ធផលបាន
- អ្នកមានធនធាន និងសមត្ថភាពគ្រប់គ្រាន់ដែរឬទេ ?
- មានភាពប្រាកដប្រជា
- ពេលវេលាច្បាស់លាស់ (ប្រើពេលប៉ុន្មាន? ផ្តើម-បញ្ចប់នៅពេលណា?)

បើសិនជាគោលបំណងមានលក្ខណៈទាំង ៥ ខាងលើនោះមានន័យថា គោលបំណងដែលអ្នកសរសេរនេះមានភាពត្រឹមត្រូវអាចយកទៅអនុវត្តបាន ។

**ឧទាហរណ៍ : លទ្ធផលរំពឹងទុក**

សហគមន៍នេសាទចំនួន ១៧៤ នឹងទទួលបានការទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ឧទាហរណ៍ផ្សេងទៀត**

- បទល្មើសនេសាទនៅសហគមន៍បានថយចុះ ២០ ភាគរយ
- ព្រៃលិចទឹក និងដែនជំរកសម្រាប់ត្រីពង-កូនកើនឡើង ១៥ ហិកតា
- រើសបានសមាជិកសហគមន៍នេសាទ ២៥៥ នាក់

## ង. ការកំណត់សកម្មភាពចំបង និងធាតុផ្សេងៗនៃតារាងផែនការ

ក្រោយពីបានគិតគូរល្អិតល្អន់និងកំណត់គោលបំណង និងលទ្ធផលរំពឹងទុករួចមកគណៈកម្មការសហគមន៍នេសាទគួរជ្រើសរើសយក **សកម្មភាពសំខាន់ៗ** ដែលបានគិតឃើញថា នឹងអាចសម្រេចបាននៅខែក្រោយ ឬក្នុងកំលុងពេល ៣ខែក្រោយ ។ សរសេរសកម្មភាពទាំងនោះ តាមលំដាប់លំដោយនៅក្នុងតារាងផែនការ ឬប្រតិទិនដូចខាងក្រោមនេះ ។

សហគមន៍នេសាទត្រូវប្រមូលព័ត៌មាន និងស្វែងយល់ផងដែរនូវធនធានពាក់ព័ន្ធ ដែលជួយឱ្យការរៀបចំផែនការសកម្មភាពអាចសម្រេចបានដោយជោគជ័យ ដែលមាននៅក្នុងភូមិសាស្ត្ររបស់ខ្លួន។ ធនធានទាំងនោះមាន: ធនធានធម្មជាតិ ធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ/ធនធានសម្ភារៈ ។

***ធនធានធម្មជាតិ :***

គឺជាធនធានដែលកើតឡើងដោយឯកឯង មិនមានអ្នកណាបង្កើតវាឡើយ ។ ធនធានធម្មជាតិចែកជា២: ធនធានធម្មជាតិកើតឡើងវិញ (កើតឡើងវិញដោយខ្លួនឯង និងមានប្រភពមិនចេះអស់) និងធនធានធម្មជាតិមិនកើតឡើងវិញ (ប្រើទៅអស់ ឬក្នុងលក្ខខណ្ឌកំណត់ណាមួយ) ។

***ចូរចងចាំ*** ការប្រើប្រាស់ដោយមិនមានចីរភាពនូវធនធានធម្មជាតិដែលកើតឡើងវិញ អាចក្លាយជាធនធានធម្មជាតិមិនកើតឡើង ។

| ធនធានធម្មជាតិកើតឡើងវិញ | ធនធានធម្មជាតិមិនកើតឡើងវិញ |
|---|---|
| ត្រី ខ្យល់ ព្រះអាទិត្យ ដី ព្រៃឈើ សត្វព្រៃ... | ឧស្ម័នធម្មជាតិ មាស ត្បូងថ្ម រ៉ែត្បូង ភ្នំ ប្រេងនៅ... |

***ធនធានមនុស្ស:***

គឺជាសមត្ថភាព តួនាទី ទេពកោសល្យ និងជំនាញនានា ដែលអាចជួយឱ្យមានការអភិវឌ្ឍក្នុងសហគមន៍ ។ **ឧទាហរណ៍** ជាងទូក ជាងផ្ទះ គ្រូពេទ្យ គ្រូបង្រៀន ហោរា ឆ្មប អ្នកនេសាទ កសិករ ប៉ូលីស... ។

***ហេដ្ឋារចនាសម្ព័ន្ធ ឬធនធានសម្ភារៈ:***

គឺជាស្នាដៃដែលកើតឡើងដោយកំលាំងកាយ និងបញ្ញារបស់មនុស្ស ខុសគ្នាពីធនធានធម្មជាតិដែលកើតឡើងដោយឯកឯង: ឧទាហរណ៍ដូចជា ស្ពាន ថ្នល់ សាលារៀន វត្តអារ៉ាម...។

ដើម្បីរៀបចំផែនការសកម្មភាពឱ្យបានល្អ គណៈកម្មការសហគមន៍នេសាទត្រូវពិចារណាចំពោះសកម្មភាពនីមួយៗដូចខាងក្រោម:

- ពិនិត្យមើលសកម្មភាពណាមួយដែលចាំបាច់ត្រូវធ្វើនៅខែក្រោយ ឬរយៈពេល២-៣ ខែខាងមុខ
- សរសេរសកម្មភាពទៅក្នុងកូលោនសកម្មភាព ក្នុងតារាងផែនការសកម្មភាព ដូចដែលបានភ្ជាប់មកជាមួយនៅខាងក្រោម
- នៅក្នុងសកម្មភាពមេនីមួយៗ ត្រូវរៀបរាប់សកម្មភាពលំអិត (បើសិនជាមាន)

- បញ្ជាក់ច្បាស់លាស់ពីពេលវេលា អ្នកទទួលខុសត្រូវ អ្នកចូលរួម និងតម្រូវការផ្សេងៗ (តារាងផែនការ)

**ឧទាហរណ៍ខ្លះៗនៃសកម្មភាពសំខាន់ៗរបស់សហគមន៍នេសាទដែលត្រូវអនុវត្ត**

- ពង្រឹងសមត្ថភាពសមាជិកគណៈកម្មការសហគមន៍នេសាទ
- សកម្មភាពផ្សព្វផ្សាយលើកកំពស់ការយល់ដឹងពីបរិស្ថានជលផល និងសារៈសំខាន់នៃសហគមន៍នេសាទ
- បង្កើនការចូលរួមគ្រប់គ្រងធនធានជលផលដោយសមាជិកសហគមន៍នេសាទ
- ចុះឈ្មោះសមាជិកសហគមន៍
- កំណត់ព្រំប្រទល់ដែននេសាទសហគមន៍
- កសាង-ពង្រឹងទំនាក់ទំនង និងកិច្ចសហការណ៍ជាមួយស្ថាប័នពាក់ព័ន្ធសំខាន់ៗ
- ប្រជុំប្រចាំខែ (រវាងសមាជិកគណៈកម្មការ និងជាមួយសមាជិកសហគមន៍នេសាទ)
- ចាត់ចែងការងារល្បាត
- គ្រប់គ្រងកន្លែងអភិរក្សជលផល
- រៀបចំចងក្រងឯកសារផ្សេងៗដូចជា: លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង ផែនការសកម្មភាព របាយការណ៍ប្រចាំខែ កំណត់ហេតុ ។ល។
- ដោះស្រាយបញ្ហា ឬ ទំនាស់ (ការកាប់រានដីព្រៃលិចទឹក ពិភាក្សាលើការផាកពិន័យពីជនល្មើស)
- ការពារព្រៃលិចទឹក និងការដាំកូនឈើឡើងវិញ
- សកម្មភាពអភិវឌ្ឍន៍ភូមិ-ឃុំ
- សកម្មភាពបន្ទាន់ចំពោះមុខ (ពន្លត់ភ្លើងឆេះព្រៃ ទទួលភ្ញៀវទស្សនៈកិច្ចសិក្សា)



រូបភាពទី២: បទបង្ហាញសកម្មភាពសំខាន់ៗ ដែលគណៈកម្មការសហគមន៍នេសាទត្រូវធ្វើ (ស.ន បាក់ទូក បាត់ដំបង)

***ឧទាហរណ៍:*** **តារាងម៉ាទ្រិកនៃផែនការសកម្មភាព**

| សកម្មភាព | គោលបំណង | តម្រូវការសំភារៈ | អ្នកទទួលខុសត្រូវ | ពេលវេលា | ទីកន្លែង |
|---|---|---|---|---|---|
| **១. ការប្រជុំ ប្រចាំខែ** | - ពង្រឹងការងារ<br>- រាយការណ៍ការងារ<br>- កែលំអអនុវត្ត<br>- រៀបចំផែនការបន្ត | ប៊ិច<br>សៀវភៅ<br>កន្លែងប្រជុំ<br>អាហារសម្រន់ | គណៈកម្មការ<br>សហគមន៍នេសាទ | រៀងរាល់<br>ថ្ងៃទី ០២<br>រាល់ខែ | ផ្ទះប្រធានភូមិ |
|  | |  |  |  |  |
|  | |  |  | | |
|  | | |  | | |
|  | | |  | | |

*ឧទាហរណ៍* : តារាងប្រតិទិនផែនការសកម្មភាព សម្រាប់ខែ សីហា ឆ្នាំ ២០០៦ របស់ស.ន ......................

| ចន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ | អាទិត្យ |
|---|---|---|---|---|---|---|
| | ១ | ២ ប្រជុំប្រចាំខែ | ៣ | ៤ | ៥ ចុះល្បាតនៅបឹងរំពេ | ៦ |
| ៧ | ៨ ធ្វើសេចក្ដីព្រាងលក្ខន្តិកៈ | ៩ | ១០ ដាក់ផ្លាកសញ្ញានៅកន្លែងអភិរក្ស | ១១ | ១២ | ១៣ |
| ១៤ | ១៥ | ១៦ ចុះល្បាតនៅបឹងទ្រនុំជ្រីង | ១៧ ចុះល្បាតនៅបឹងរំពេ | ១៨ | ១៩ | ២០ |
| ២១ ចុះល្បាតនៅបឹងអាផៃ | ២២ | ២៣ | ២៤ | ២៥ | ២៦ ចុះឈ្មោះសមាជិក | ២៧ |
| | | ៣០ ប្រជុំជាមួយអង្គការអភិវឌ្ឍន៍ស្ត្រី | ៣១ | | | |

### ច. ការស្នើគាំទ្រពីអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ

ការសហការពីសំណាក់អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធមានសារៈសំខាន់ណាស់ ដូចនេះគណៈកម្មការសហគមន៍នេសាទ ត្រូវធ្វើយ៉ាងណាបញ្ចុះបញ្ចូលដល់ក្រុមប្រឹក្សាឃុំ, មន្ត្រីរដ្ឋបាល និងអ្នកពាក់ព័ន្ធនានាឱ្យសហការ និងគាំទ្រដល់ដំណើរការសហគមន៍នេសាទ ដូចជាបច្ចេកទេស ថវិកា និងជាពិសេសការបង្ក្រាបបទល្មើសនេសាទជាដើម ។

### ឆ. ការអនុវត្តផែនការសកម្មភាព និងការត្រួតពិនិត្យ

រៀងរាល់ខែគណៈកម្មការសហគមន៍នេសាទ ត្រូវរៀបចំការប្រជុំរួមរបស់ខ្លួន ដើម្បីធ្វើសេចក្ដីរាយការណ៍ពីលទ្ធផលសម្រេចបាន ដោយធ្វើកិច្ចការរួមគ្នាក្នុងការសរសេររបាយការណ៍ បន្ទាប់មកលេខាធិការត្រូវប្រមូលលទ្ធផលដើម្បីចងក្រងទុកជាលទ្ធផលប្រចាំខែ ។ ក្នុងនោះដែរគណៈកម្មការសហគមន៍នេសាទ ត្រូវរៀបចំការប្រជុំរៀបចំ

ផែនការសកម្មភាពប្រចាំខែ ឬត្រីមាស ហើយផ្ញើជូនស្ថាប័នពាក់ព័ន្ធ មានប្រធានភូមិ ក្រុមប្រឹក្សាឃុំ អង្គការក្រៅរដ្ឋាភិបាល សង្កាត់នេសាទ អ្នកសម្របសម្រួល និងការិយាល័យជលផលខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ប្រចាំខែ ។

- ធ្វើការងារទៅតាមផែនការ-ជូនដំណឹងទៅគ្រប់អ្នកធ្វើសកម្មភាព និងត្រៀមសម្ភារៈឧបករណ៍
- ធានាថាការត្រួតពិនិត្យការងារកើតឡើង
- មានការកត់ត្រាព្រឹត្តិការណ៍ត្រឹមត្រូវ
- មានការប្រជុំជាទៀងទាត់
- ប្រកាន់យកភាពបត់បែនខ្លះ-ជួនពេលខ្លះ មានការងារខ្លះដែលយើងមិនរំពឹងទុកកើតឡើង



រូបភាពទី៣: បទបង្ហាញផែនការសកម្មភាពរបស់គណៈកម្មការសហគមន៍នេសាទព្រែកត្រប់ ខេត្តបាត់ដំបង

| តារាងសង្ខេបជំហាននៃការរៀបចំផែនការសកម្មភាព | | |
|---|---|---|
| **ជំហាន** | **ចំណុចសំខាន់ៗត្រូវពិចារណា** | **តួនាទីអ្នកសម្របសម្រួល** |
| ក. ការរំលឹកឡើងវិញពីសកម្មភាពដែល គ.ស.ន.បានធ្វើកន្លងមក | ***ភាពទូលំទូលាយនៃការរៀបចំផែនការសកម្មភាពល្អត្រូវកំណត់ដោយៈ***<br>▪ ចំនួនព័ត៌មានដែលអាចរកបាន ( មានព័ត៌មានច្រើន និង វិភាគគ្រប់ជ្រុងជ្រោយ)<br>▪ ចំនួន និងសមត្ថភាពរបស់អ្នកចូលរួម | ▪ ប្រើប្រាស់ទិន្នន័យពីការធ្វើ PRA<br>▪ ទិន្នន័យពីស្ថានភាពសហគមន៍<br>▪ ព័ត៌មានពីការវិភាគធនធានដែលមាននៅក្នុងសហគមន៍ ( ប្រសិនបើមាន)<br>▪ ព័ត៌មានដែលទទួលបានក្នុងពេលធ្វើការពិគ្រោះយោបល់ |
| ខ. ការកំណត់បញ្ហាសំខាន់ៗដែលពុំទាន់ដោះស្រាយ និងបន្តដោះស្រាយ | ***ការកំណត់បញ្ហាសំខាន់ៗត្រូវៈ***<br>▪ កំណត់បញ្ហាដែលមានស្រាប់ នឹងអាចកើតមាន<br>▪ ផ្តោតលើចំណុចសំខាន់ៗទាក់ទងទៅនឹងធនធានជលផល ធនធានធម្មជាតិ( ព្រៃលិចទឹក សត្វ ដី...)<br>▪ ចំណុចខ្វះខាត ក្នុងដំណើរការបង្កើតសហគមន៍ (លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រង)<br>▪ សមត្ថភាពគណៈកម្មការសហគមន៍នេសាទ និងការយល់ដឹងរបស់សមាជិក<br>▪ ទំលាប់នៃការប្រកបរបរចិញ្ចឹមជីវិត( ការរានដីព្រៃលិចទឹក ការប្រើប្រាស់ថ្នាំពុលគីមីកសិកម្ម) | ▪ ទាញយកបញ្ហានានានៅសហគមន៍<br>▪ បង្កលក្ខណៈឱ្យសិក្ខាកាមមានឱកាសធ្វើការពិភាក្សាបានទូលំទូលាយ (យុវជនអ្នកងាយរងគ្រោះស្ត្រីមេម៉ាយ)<br>▪ ធ្វើការបូកសរុបដោយអ្នកសម្របសម្រួល ។ |
| គ. ការចាត់អាទិភាពបញ្ហា | ***ការចាត់អាទិភាពបញ្ហាសំខាន់ៗត្រូវៈ***<br>▪ ធ្វើចំណាត់ថ្នាក់បញ្ហា ដែលបានលើកឡើងដោយ<br>▪ សិក្ខាកាម ( សំខាន់ណាស់ សំខាន់ បន្ទូរ មធ្យម)<br>▪ ប្រើប្រាស់តារាងប្រៀបធៀបភាពសំខាន់នៃបញ្ហា (ម៉ាទ្រិច ការពិភាក្សា និងព្រមព្រៀងមតិ) | ▪ បំផុសគំនិតដល់សិក្ខាកាម<br>▪ ពិភាក្សាជារួមជាមួយសិក្ខាកាម<br>▪ បង្ហាញវិធីចាត់អាទិភាពបញ្ហា<br>▪ សរសេរចូលក្នុងក្រដាសធំទូរលទ្ធផល<br>▪ ធ្វើបង្ហាញដល់ក្រុមធំបូកសរុប/សំយោគ |

| | | |
|---|---|---|
| ឃ. ការកំណត់/បង្កើតគោលបំណង និងលទ្ធផលរំពឹងទុក | ▪ យកបញ្ហានីមួយ១ មកសរសេរគោលបំណង (ប្រយោគវិជ្ជមាន – ដែលបង្ហាញពីអ្វីដែលអ្នកទទួលផល នឹងទទួលបាន)<br>▪ សរសេរលទ្ធផលរំពឹងទុក | ▪ ពាក្យគន្លឹះ ដើម្បីបង្កើតជាគោលបំណងឆ្លើយតបទៅនិងបញ្ហា<br>▪ ការពិភាក្សា និងព្រមព្រៀងមតិលើគោលបំណងត្រូវគិតពី**ស្មាត**ដែលមានចំណុចសំខាន់៥:<br>• មានលក្ខណៈជាក់លាក់ ច់១<br>• អាចវាស់វែង<br>• អាចសម្រេចបាន<br>• ប្រាកដប្រជា<br>• មានពេលវេលាជាក់លាក់<br>▪ ស្នើសិក្ខាកាមសរសេរសាកល្បង |
| ង. ការកំណត់សកម្មភាពចំបង និងធាតុផ្សេងនៃតារាងផែនការ | ▪ ប្រើប្រាស់តារាងម៉ាទ្រិច ដោយផ្តោតលើ:<br>១. សកម្មភាព<br>២. ទីកន្លែង<br>៣. តម្រូវការធនធាន<br>៤. អ្នកទទួលខុសត្រូវ<br>៥. ពេលវេលា (រយៈពេល)<br>▪ តារាងប្រតិទិនផែនការសកម្មភាព តាមខែនីមួយ១ | ▪ បែងចែកក្រុមពិភាក្សា<br>▪ ដឹកនាំការពិភាក្សាអំពីតារាងផែនលើកឧទាហរណ៍<br>▪ ធ្វើបទបង្ហាញតាមក្រុមនីមួយ១ ប្រើ ***ស្មាត*** ដើម្បីកែតម្រូវ និងធ្វើការសម្រេច<br>▪ ធ្វើការសំយោគលទ្ធផល |
| ច. ការស្នើគាំទ្រពីសំណាក់អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ | ▪ បញ្ចុះបញ្ចូលក្រុមប្រឹក្សាឃុំ និងប៉ុស្តិ៍រដ្ឋបាលឱ្យសហការ និងគាំទ្រដល់ដំណើរការសហគមន៍នេសាទជាពិសេសដល់ការបង្ក្រាបបទល្មើសនេសាទជាដើម | ▪ ជូនកាលត្រូវនាំឱ្យគេជួបគ្នាញឹកញាប់<br>▪ បង្ហាញពីសុឆន្ទៈចង់ធ្វើជាមួយស.គ.ន.<br>▪ ប្រជុំជាញឹកញាប់<br>▪ ស្នើអ្នកមានបទពិសោធន៍ ចែករំលែកបទពិសោធន៍និងចំណេះដឹងរបស់ខ្លួន |
| ឆ. ការអនុវត្តផែនការសកម្មភាព និងការត្រួតពិនិត្យ | ▪ ធ្វើការងារទៅតាមផែនការ–ជូនដំណឹងទៅគ្រប់អ្នកធ្វើសកម្មភាព និងត្រៀមសម្ភារៈឧបករណ៍<br>▪ ធានាថាការត្រួតពិនិត្យការងារកើតឡើង<br>▪ មានការកត់ត្រាព្រឹត្តិការណ៍ត្រឹមត្រូវ<br>▪ មានការប្រជុំជាទៀងទាត់ ប្រកាន់យកភាពបត់បែនខ្លះ ជួនពេលខ្លះមានការងារខ្លះដែលយើងមិនរំពឹងទុកកើតឡើង | ▪ ឧស្សាហ៍ចុះមូលដ្ឋាន<br>▪ ផ្តល់ភាពកក់ក្តៅ<br>▪ សង្កេតគ្រប់ជ្រុងជ្រោយ<br>▪ ពង្រឹងគណៈកម្មការសហគមន៍បន្ថែមទៀតបើចាំបាច់ |

## ៧. ឯកសារពិគ្រោះ


- អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ មិថុនា ២០០៥
- សុវណ្ណ, កក្កដា ២០០៥. ការកសាងផែនការសម្រាប់គ្រប់គ្រងសហគមន៍ព្រៃឈើ
- Peter Degen, May 2005, *Technical Guideline on CFAMP for TSEMP-C2*
- Peter Degen, March 2003, *Working Group and Site Assessment Concept Notes of TSEMPC2*
- Phill Bartie, 1998, *Handbook for Mobilizers.*
- ច្បាប់ជលផល. ១៩៨៤




រូបភាពទី៤ : អ្នកសម្របសម្រួលខេត្តពោធិ៍សាត់ព្យាយាមជួយសហគមន៍នេសាទ ទោះមានឧបសគ្គក៏ដោយ

## ៨.ឯកសារជំនួយ: (ជំហានក្នុងការរៀបចំផែនការ)

**ជំហានទី ១:** ការវិភាគស្ថានភាព

***ក. ការវិភាគការចូលរួម***

***ខ. ការវិភាគបញ្ហា***

***គ. ការវិភាគគោលបំណង***

***ឃ. ការវិភាគ វិធីសាស្ត្រដោះស្រាយបញ្ហា ឬជម្រើស***

***ក. ការវិភាគការចូលរួម:***

ក្នុងដំណាក់កាលដំបូងនេះ ក្រុមអ្នកវិភាគ ត្រូវធ្វើការវិភាគទៅលើក្រុម និងស្ថាប័ន ឬអង្គភាព ដែលមានធ្វើសកម្មភាពនៅក្នុងតំបន់ដែលយើងសិក្សានោះ។ ត្រូវរកឱ្យឃើញថាតើមានក្រុម និងស្ថាប័នណាខ្លះ នៅទីនោះមានភាពដូចគ្នា និងខុសគ្នាអ្វីខ្លះ ។ ក្រុមណាជាក្រុមចូលរួម ក្រុមណាមិនចូលរួម ។ ក្រុមដែលចូលរួមមានក្រុមណាដែលសកម្មទទួលផល និងមានឥទ្ធិពល។ ហើយចំពោះក្រុមមានឥទ្ធិពលតើក្រុមណាជាអ្នកគាំទ្រ និងក្រុមណាជាក្រុមជំទាស់ ។ល។

***ខ. ការវិភាគបញ្ហា:***

**ការបង្កើតបញ្ហាត្រូវ :**

- កំណត់បញ្ហាដែលមានស្រាប់ ដែលមិនអាចធ្វើបាន បញ្ហាដែលស្រមៃ ឬ បញ្ហាដែលអាចកើតនៅពេលអនាគត
- បញ្ហាមិនមែនអវត្តមាននៃដំណោះស្រាយនោះទេ ក៏ប៉ុន្តែជាលក្ខណៈអវិជ្ជមានដែលមានក្នុងសភាពជាក់ស្តែង (ត្រូវកំណត់បញ្ហាឱ្យមានច្រកចេញ)។

**__ឧទាហរណ៍:__** ថ្នាំពុលមិនអាចរកបាន (ខុស) ដំណាំស្រូវបានបំផ្លាញដោយកន្លាតចង្រៃ (ត្រូវ) ក្នុងការវិភាគនេះត្រូវប្រមូលឱ្យបាននូវបញ្ហាដែលមានក្នុងមូលដ្ឋាននោះ វិភាគរកមើលបញ្ហាណាដែលជាបញ្ហាចំបងជាងគេហៅថា Core Problem ។ វិភាគរកមូលហេតុដែលបណ្តាលឱ្យកើតមានបញ្ហានេះឡើង និងបន្ទាប់មកទៀតវិភាគរកមើលនូវឥទ្ធិពលដែលអាចកើតឡើងមកពីបញ្ហានេះ ។ ការវិភាគនេះបង្កើតបានជាដើមឈើបញ្ហាមួយ ។ គួរកត់សំគាល់ថាឃ្លាទាំងឡាយដែលមាននៅក្នុងដើមឈើបញ្ហានេះសុទ្ធតែជាឃ្លាអវិជ្ជមាន ។

***គ. ការវិភាគគោលបំណង:***

(មើលពីលើចុះក្រោម) កែប្រែខ្លះអវិជ្ជមាន-វិជ្ជមាន ជារួមការវិភាគគោលបំណង គឺជាការបំលែងដើមឈើបញ្ហា ឱ្យទៅជាដើមឈើគោលបំណង។ ក្នុងដើមឈើគោលបំណងឃ្លាទាំងអស់សុទ្ធតែមានលក្ខណៈវិជ្ជមាន។ គួរកត់សំគាល់ថា ការវិភាគត្រូវមានលក្ខណៈសមហេតុផលមានទំនាក់ទំនង តាំងពីបុព្វហេតុដល់ឥទ្ធិពលដែលធ្វើឱ្យក្លាយទៅជាមធ្យោបាយមួយដ៏ល្អ ដើម្បីទទួលបានជោគជ័យ។ របៀបមើលពីលើចុះមកក្រោមបំលែងបណ្តាបញ្ហាទាំងអស់ឱ្យទៅជាគោលបំណង។

**ឃ. ការវិភាគវិធីសាស្ត្រដោះស្រាយបញ្ហា** (Alternative Analysis)៖

បណ្តាដំណោះស្រាយទាំងអស់ដែលបានរកឃើញ ត្រូវបែងចែកជាជំរើសនៃការដោះស្រាយផ្សេងៗដូចជាៈ ដំណោះស្រាយដោយផលិតកម្ម ការបង្កើតប្រាក់ចំណូល ការបណ្តុះបណ្តាលជាដើម ។ល។ ដើម្បីវាយតម្លៃទៅលើដំណោះស្រាយទាំងនេះ ចាំបាច់ត្រូវបង្កើតលក្ខណៈវិនិច្ឆ័យហើយ ត្រូវជ្រើសរើសយកមួយណាដែលមានសារៈប្រយោជន៍ដល់ក្រុមគោលដៅជាងគេជៀសវាងធ្វើទៅបានតែផលប្រយោជន៍ខ្លួនឯង និងតម្រូវទៅតាមគោលនយោបាយរបស់រដ្ឋាភិបាល (ក្រុមគោលដៅ គឺជាអ្នកដែលទទួលផលពីយើង) ។ លក្ខណៈវិនិច្ឆ័យសំខាន់ៗ មួយចំនួនៈ

- ធនធានដែលយើងមាន
- សារៈសំខាន់របស់គំរោងទៅនឹងក្រុមគោលដៅ
- លទ្ធភាពនៃការទទួលជ័យជំនះ
- ទំនាក់ទំនងទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាល
- ភាពចាំបាច់
- ពេលវេលាដែលអាចធ្វើបានរបស់អ្នក
- សកម្មភាពរបស់អង្គភាពអ្នក

**ជំហានទី ២ៈ** ការរៀបចំគម្រោង

- បង្កើតតារាង Logical framework (ធាតុនៃគំរោង)
- កត្តាវាស់វែងខាងក្រៅ Performance Measurement
- សន្មត់ស្សន៍ Performance Measurement

**ការរៀបចំគម្រោងកម្មវិធីៈ**

របៀបសមហេតុផល គឺជាបណ្តុំគំនិតទាក់ទងគ្នា ដែលបង្ហាញក្នុងវិធីប្រតិបត្តិមួយ មានទម្រង់ជាម៉ាទ្រិក។ ទម្រង់នេះ ផ្តល់របៀបពិនិត្យមើលថា តើការប្រតិបត្តិត្រូវបានរៀបចំល្អ ឬទេ និងវាជួយសម្រួលដល់ការត្រួតពិនិត្យ និងវាយតម្លៃ។

**តារាងតក្កភាព (Logical Framework)**

| លំដាប់អន្តរាគមន៍<br>Intervention Logic | សន្ទស្សន៍<br>Indicators | មធ្យោបាយផ្ទៀងផ្ទាត់<br>Means of Verification | កត្តាចៃដន្យ<br>Risks / Assumptions |
|---|---|---|---|
| **គោលបំណងរួម** | | | |
| **លទ្ធផលគម្រោង** | | | |
| **សកម្មភាព** | | | |

**លំដាប់អន្តរាគមន៍**



## ធនធានស្មារតី និងសំភារៈដែលចាំបាច់សម្រាប់ធ្វើសកម្មភាព

**លំដាប់លំដោយនៃផែនការៈ**

**គោលបំណងរួមៈ** មានទំហំធំជាងគោលបំណងគម្រោងជាក់លាក់។ គម្រោង និងសកម្មភាពផ្សេង១រួមចំណែកដើម្បីទទួលបានគោលបំណងរួមនេះ ។

**គោលបំណងជាក់លាក់ៈ** ទទួលបានដោយការអនុវត្តន៍គម្រោង ជាការចង់បានដោយសកម្មភាពមេ ឬផ្នែកនីមួយ១

**លទ្ធផលៈ** ផលិតផលនៃសកម្មភាពដែលបានអនុវត្តន៍

**សកម្មភាពៈ** អំពើដែលត្រូវធ្វើដើម្បីទទួលបានលទ្ធផល ។

**សន្ទស្សន៍ៈ** បរិយាយអំពីការអនុវត្តនៃគោលបំណងរួម គោលបំណងគម្រោងលទ្ធផលជាបរិមាណ និងគុណភាព ដែលបង្ហាញពីពេលវេលា ទីកន្លែង ។

**មធ្យោបាយផ្ទៀងផ្ទាត់ៈ** បង្ហាញពីទីកន្លែង ព័ត៌មាន ប្រភេទ ដើម្បីឱ្យយើងដឹងពីការទទួលបាន នូវគោលបំណងរួម គោលបំណងគម្រោង លទ្ធផល និងសកម្មភាព (ដែលបានបង្ហាញដោយសន្ទស្សន៍) ។

**កត្តាសន្មតៈ** ស្ថិតនៅខាងក្រៅការគ្រប់គ្រងគម្រោង ប៉ុន្តែមានសារៈសំខាន់សម្រាប់ទទួលបាននូវសកម្មភាព លទ្ធភាព គោលបំណងជាក់លាក់ និងគោលបំណងរួម ។ លំដាប់អន្តរាគមន៍មិនមានលក្ខណៈ ពិតទាំងអស់ឡើយ កត្តាខាងក្រៅរមែងមានឥទ្ធិពលសំខាន់ទៅលើភាពជោគជ័យរបស់គម្រោង ដូច្នេះយើងត្រូវកំណត់ និងដាក់វាបញ្ចូលទៅក្នុងការពិចារណារបស់យើង ។ គោលបំណងខ្លះ ដែលមាននៅក្នុងដើមឈើគោលបំណងអាចជាកត្តាខាងក្រៅ ហើយកត្តាខាងក្រៅផ្សេងទៀត ត្រូវបានកំណត់ឡើងដោយក្រុមអ្នកឯកទេស ឬក្រុមអ្នកចូលរួម ។

**កត្តាធានានូវនិរន្តរភាពៈ** គម្រោងមួយមាននិរន្តរភាព ពេលដែលវាអាចមានផលប្រយោជន៍ទៅដល់ក្រុមគោលដៅក្នុងរយៈពេលខាងមុខ បន្ទាប់ពីបានបញ្ចប់ជំនួយរបស់អ្នកផ្តល់ទុន ។

កត្តាដែលអាចមានឥទ្ធិពល ដល់និរន្តរភាពត្រូវពិចារណាលើចំណុចខាងក្រោមនៅពេលរៀបចំ និងអនុវត្តគម្រោង ។

- វង្វាស់ពីការគាំទ្រគោលនយោបាយ
- បច្ចេកទេសសមស្រប
- ការការពារបរិស្ថាន
- ផ្នែកវប្បធម៌សង្គម ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍
- សកម្មភាពគ្រប់គ្រង និងការអភិវឌ្ឍស្ថាប័ន
- ផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




រដ្ឋបាលជលផល
អាគារលេខ ១៨៦ មហាវិថីព្រះនរោត្តម
ប្រអប់សំបុត្រ ៥៨២ ភ្នំពេញ កម្ពុជា
អ៊ីម៉ែល: cfdd@yahoo.com

Fisheries Administration
#186 Preah Norodom Blvd. P.O. Box 582,
Phnom Penh Cambodia
Email: cfdd@yahoo.com